# មន្ទីរកសិកម្មខេត្តកណ្ដាល

## ល្ហុង




អាស័យដ្ឋានទំនាក់ទំនង: ផ្លូវលេខ ១០៣ (តាខ្មៅ)

ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១)

(០១២ ៨២៤ ៤២៥)



ឧបត្ថម្ភដោយៈ អង្គការវីវីអូប៊ី VVOB

vvob education for development

ឆ្នាំ ២០១០


# ដំណាំល្ហុង

## ១- សេចក្ដីផ្ដើម

ល្ហុងជាដំណាំមួយប្រភេទ ដែលមានសារៈសំខាន់ចំពោះមនុស្ស និងសត្វ។ វាជាប្រភពមួយផ្ដល់នូវជីវជាតិផ្សេងៗគ្នាដូចជាអង្គធាតុរ៉ែ សាធាតុសរីរាង្គ វីតាមីនអា និងវីតាមីនសេ ដែលមានប្រយោជន៍ចាំបាច់សំរាប់មនុស្ស។ ការបរិភោគផ្លែល្ហុងទុំអាចជួយក្នុងការរំលាយអាហារ។ នៅប្រទេសកម្ពុជាយើង ដំណាំល្ហុងត្រូវបានគេដាំតាំងពីយូរយារណាស់មកហើយ តែគេដាំសំរាប់ផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ និងសល់ពីការហូបចុកខ្លះគេអាចយកទៅលក់នៅទីផ្សារ។ ផ្លែល្ហុងខ្ចីគេអាចយកទៅធ្វើជាបន្លែសំរាប់ស្ល ជ្រក់ ស្ងោរស៊ុប។ល។

**<u>សារៈប្រយោជន៍នៃដំណាំល្ហុងៈ</u>**

ក្នុងជីវភាពរស់នៅ គេអាចយកផ្លែល្ហុងមកប្រើប្រាស់បានច្រើនយ៉ាង ដោយវាសំបូរទៅដោយវីតាមីនជាច្រើនហើយក៏ជាអាហារដ៏ប្រសើរសំរាប់មនុស្សពេញវ័យ និងកុមារ។ ផ្លែល្ហុង គេអាចយកមកប្រើប្រាស់បាន ២យ៉ាង គឺសំរាប់ហូបជាអាហារស្រស់ និងជាផលិតផលកែច្នៃ ។

ប្រើសំរាប់ជាអាហារស្រស់ គឺគេបរិភោគផ្លែស្រស់ និងសំរាប់ហូបជាបន្លែផ្សេងទៀត ដូចជា ស្ល ជ្រក់ ស្ងោរ......

ប្រើសំរាប់ជាផលិតផលកែច្នៃ គឺទាំងផ្លែនៅខ្ចី និងទុំគេអាចយកទៅធ្វើជាអាហារកំប៉ុង ស្រា ទឹកផ្លែឈើ ដំណាប់.....

ផ្លែទុំគេអាចយកធ្វើជាថ្នាំសំរាប់ព្យាបាលជម្ងឺក្រពះឯផ្លែខ្ចីវិញគេអាចយកជ័រដែលមានជាតិប៉ាប៉ែនសំរាប់ជួយដល់ដំណើរឈាមរត់នៅក្នុងខ្លួនរបស់យើង និងជួយដល់សាច់ដុំធ្វើថ្នាំដុសធ្មេញ ថ្នាំសំរាប់សំអាតស្បែក និងម្សៅលាបមុខ។ ចំណែកឯស្លឹក គេអាចយកធ្វើថ្នាំសំរាប់ព្យាលបាលជម្ងឺហើមស្លឹក និងឫសធ្វើថ្នាំព្យាលបាលសរសៃប្រសាទ គ្រាប់វាចំរាញ់ធ្វើប្រេង ។

## ២- ពូជ

នៅក្នុងប្រទេសកម្ពុជាយើង ពូជល្ហុងមានពីរប្រភេទគឺ ពូជល្ហុងលក្ខ័ និង ពូជល្ហុងដំឡូង ឬ ល្ហុងពងមាន់ ។

**<u>ពូជល្ហុងលក្ខ័ៈ</u>**

ពូជល្ហុងប្រភេទនេះ គេនិយមចូលចិត្តដាំជាងពូជល្ហុងដំឡូង ឬ ល្ហុងពងមាន់ព្រោះវាមានឱជារសឆ្ងាញ់ពិសា។ ពូជល្ហុងប្រភេទនេះមានដើមពណ៌ស្វាយរហូតដល់ធាង។ ផ្លែវាមានពណ៌បៃតងខ្ចី ផ្លែរាងទ្រវែង មានគ្រាប់តិចនៅពេលទុំមានសំបកពណ៌លឿង និងសាច់ក្រហម។

**<u>ពូជល្ហុងដំឡូង ឬល្ហុងពងមាន់ៈ</u>**

ពូជល្ហុងប្រភេទនេះ គេពុំសូវនិយមចូលចិត្តដាំប៉ុន្មានទេ ព្រោះវាពុំសូវមានរសជាតិផ្អែមឆ្ងាញ់ពិសា ប៉ុន្តែវាងាយស្រួលក្នុងការដាំដុះជាងពូជល្ហុងលក្ខ័។ ដើម និងផ្លែមានពណ៌បៃតងពេលទុំមានពណ៌លឿង ពុំសូវផ្អែមហើយមានគ្រាប់ច្រើន។

## ៣. វិធីសាស្ត្រក្នុងការដាំដុះ

**<u>លក្ខខណ្ឌដីៈ</u>** ដំណាំល្ហុងត្រូវការដីមានសភាពធូរហើយស្រស់ទឹក និងសំបូរទៅដោយជីវជាតិ ជាពិសេសគឺដីកណ្ដេង ឬដីល្បាយខ្សាច់។

**ថ្នាលសំរាប់បណ្តុះកូនៈ** គេត្រូវរៀបចំកូនថ្នាលតូចមួយ ដែលមានទទឹង ១ម៉ែត្រ បណ្តោយ ២ម៉ែត្រ ធ្វើដំបូលអំពីឫស្សី និងប្រក់ស្លឹកដូងសំរាប់ឱ្យមានពន្លឺថ្ងៃចេញចូលបាន។ គេត្រូវច្របល់ដីល្បាយច្រកចូលទៅក្នុងកូនថង់ប្លាស្ទិក ឬកន្ទោងធ្វើពីស្លឹកត្នោត ដែលមានប្រហោងនៅបាតសំរាប់ឱ្យខ្យល់ចេញចូលបាន រួចដកកូនចេញពីថ្នាលទៅដាក់ក្នុងកូនថង់ ឬ កន្ទោងនោះសំរាប់ទុកដាំ។

គេយកគ្រាប់សាបត្រូវកប់ក្នុងជំរៅ ១០មីលីម៉ែត្រ និងចន្លោះ ១៥មីលីម៉ែត្រ ក្នុងថ្នាលបណ្តុះកូន ឬត្រូវដាំ ១គ្រាប់ក្នុងជំរៅ ១មីលីម៉ែត្រ នៅក្នុងកូនថង់ប្លាស្ទិក ឬកន្ទោង។ ៣-៤ អាទិត្យក្រោយមកគ្រាប់ទាំងនេះនឹងដុះ ហើយអាចដកកូនយកទៅដាំនៅក្នុងរយៈពេលពី ៦-១០អាទិត្យ ក្រោយពេលសាបឬដាំគ្រាប់រួច។ ទាំងនៅក្នុងថ្នាល និងកូនថង់ប្លាស្ទិក ឬកន្ទោងត្រូវឱ្យសើមជានិច្ចតែមិនត្រូវឱ្យជោគជាំពេកទេ ។

**បច្ចេកទេសដាំៈ** ការដាំត្រូវមានចំងាយពីដើមមួយទៅដើមមួយ ២-៣ម៉ែត្រ ពីគ្នា។ រណ្តៅនេះត្រូវលាយលាមកគោ ឬជីកំប៉ុស្តិឱ្យបានសព្វល្អ។ ក្នុងរណ្តៅនីមួយៗ ត្រូវស្ទូងកូនល្ហុង ១ដើម ដោយរើសយកកូនល្ហុងណាដែលថ្លោសល្អជាងគេ។

**ការថែទាំ**

ក.ការជំរះស្មៅ និងជ្រួយដីពូនគល់ៈ គេត្រូវជំរះស្មៅឱ្យបានញឹកញាប់ និងស្អាតល្អ ដើម្បីកុំឱ្យរំខានដល់ការលូតលាស់ និងដណ្តើមយកជីជាតិពីដំណាំ។ ម្យ៉ាងទៀតស្មៅអាចជាជំរកសត្វល្អិតចង្រៃ និងជម្ងឺផ្សេងៗទៀតផង។ ការទុកស្មៅឱ្យដុះនៅជុំវិញដំណាំច្រើន អាចបណ្តាលឱ្យទិន្នផលថយចុះ។ ទន្ទឹមនឹងការជំរះស្មៅ ការជ្រួយដីក៏មានសារៈសំខាន់ដែរ ដោយវាធ្វើឱ្យដីធូរងាយស្រួលខ្យល់ចេញចូល ងាយស្រួលដល់ដំណាំក្នុងការចាក់ឫស និងផ្ទុកទឹកបានល្អ។ ល្ហុងជាប្រភេទដំណាំដែលចាក់ឫសបានរាក់ និងងាយរលំដួលដោយសារខ្យល់។

ខ. ការដាក់ជីៈ ជីមានសារៈសំខាន់ណាស់សំរាប់រុក្ខជាតិក៏ដូចជាដំណាំដទៃទៀតដែរ។ ជីជួយដល់ការលូតលាស់ និងផ្តល់ផ្កាផ្លែ។ ការដាក់ជីតែមួយដងនៅមុនពេលដាំ (ទ្រាប់បាត) ឬនៅពេលស្ទូងកូនមិនបានគ្រប់គ្រាន់ទេ។

គ.ការស្រោចទឹកៈ រុក្ខជាតិត្រូវការទឹកជាចាំបាច់ ប៉ុន្តែដំណាំល្ហុងត្រូវការទឹកមិនសូវជាជោគជាំប៉ុន្មានទេ។ បើមានការខ្វះខាតទឹក ឬមានទឹកជោគជាំខ្លាំងពេក អាចបណ្តាលឱ្យការលូតលាស់របស់ដំណាំមានការថយចុះ ឬក៏ងាប់តែម្តង។ ការស្រោចទឹកត្រូវផ្លាស់ប្តូរទៅតាមពេលវេលា និងរដូវកាលទៅតាមដំណាក់កាលលូតលាស់របស់ល្ហុង។ ការស្រោចទឹកហួសក៏ធ្វើអោយដំណាំល្ហុងងាយកើតជម្ងឺដែរ។

## ៤. ការប្រមូលផល

ដំណាំល្ហុងតែងចាប់ផ្តើមឱ្យផលបន្ទាប់ពីដាំបាន ៦ ទៅ ៧ ខែ ហើយអាចប្រមូលផលបានស្ទើរតែពេញមួយឆ្នាំ។ ជាទូទៅគេសំគាល់វាថាល្មមនឹងប្រមូលផលបានគឺ មានពីរករណីៈ

- សំរាប់យកផ្លែខ្ចី គឺប្រមូលបានគ្រប់ពេលដែលផ្លែវាធំល្មមអាចបេះបាន។
- សំរាប់យកផ្លែទុំគឺ ប្រមូលបាននៅពេលផ្លែធំចាស់ និងសំបកឡើងពណ៌លឿងព្រឿងៗ (ស្រគាល) ជៀសវាងការទុំពេកនៅលើដើម ពីព្រោះវាងាយរងការបំផ្លាញរបស់សត្វដង្កូវរុយ ឬនាំឱ្យវាឆាប់រលួយ។
- ពេលវេលាល្អដែលត្រូវបេះ គឺចាប់ពីម៉ោង ៩ព្រឹក ដល់ ៣រសៀលព្រោះវាមានជាតិជ័រតិច។
- ដើម្បីការពារកុំឱ្យប្រឡាក់ផ្លែល្ហុង គឺយើងត្រូវជៀសវាងដាក់វាឱ្យប៉ះផ្ទាល់ដីបន្ទាប់ពីបេះរួច។
- ការប្រមូលផលគឺ ធ្វើដោយដៃ ឬកន្ត្រកដងវែង ហើយអាចប្រមូលបានគ្រប់ពេល លើកលែងពេលភ្លៀងដែលពិបាកនឹងបេះ។ ពេលបេះហើយត្រូវបញ្ឈរក្បាលចុះក្រោមដើម្បីកុំឱ្យវាប្រឡាក់ជ័រ។

